**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់និង នេសាទ**
**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តក្រចេះ**

លេខ............✓..............

# សេចក្ដីប្រកាសព័ត៌មាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ មានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា៖ បន្ទាប់ពីបានស្ដាប់នូវការចាក់ផ្សាយរបស់វិទ្យុអាស៊ីសេរីនាយប់ថ្ងៃសុក្រ ១៣រោច ខែពិសាខ ឆ្នាំកុរ ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩ ដែលបានធ្វើការចាក់ផ្សាយចោទប្រកាន់ "..................ថាមានការឃុបឃិតជាមួយសមត្ថកិច្ចជំនាញប្រព្រឹត្តិបទល្មើសលួចកាប់ឈើពីតំបន់ព្រៃឡង់ដឹកចូលក្រុមហ៊ុនបន្លំជាឈើស្របច្បាប់...... ..............................។ល។និង។ល។" បន្ទាប់ពីបានចុះពិនិត្យផ្ទៀងផ្ទាត់ជាក់ស្ដែងរួចមក មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ សូមធ្វើការបដិសេធទាំងស្រុងនូវខ្លឹមសារផ្សព្វផ្សាយរបស់វិទ្យុអាស៊ីសេរីដែលមានការប្រាស់ចាកការពិតទាំងស្រុងពីសកម្មភាពអនុវត្តជាក់ស្ដែងរបស់សមត្ថកិច្ចជំនាញ និងក្រុមហ៊ុន ស៊ីងបាយអូថេក (ខេមបូឌា) ខូអិលធីឌី។

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ យល់ឃើញថាខ្លឹមសារដែលបានធ្វើការផ្សព្វផ្សាយមកនេះ គឺមានចរិកចេតនាញុះញង់សាធារណៈមតិឲ្យមានការយល់ច្រឡំចំពោះគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលជានិច្ចកាលគ្រប់កាលៈទេសៈមន្ត្រីជំនាញរបស់រដ្ឋតែងតែខិតខំបំពេញភារកិច្ចស្នូលប្រកបដោយភាពទទួលខុសត្រូវខ្ពស់។

ជាថ្មីម្ដងទៀត មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ សូមធ្វើការបដិសេធទាំងស្រុងនូវព័ត៌មានដែលផ្សព្វផ្សាយដោយវិទ្យុអាស៊ីសេរីនាយប់ថ្ងៃសុក្រ ១៣រោច ខែពិសាខ ឆ្នាំកុរ ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩នោះ គឺជាព័ត៌មានមិនពិត និងបំភ្លៃសព័ត៌មានទាំងស្រុង។

អាស្រ័យហេតុនេះ សូមបណ្ដាញផ្សព្វផ្សាយព័ត៌មាន និងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ ............ ខែ ............ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ក្រចេះ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០១៩
**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត**

អាសយដ្ឋាន ផ្លូវព្រះសុរាម្រឹត សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ
Address Preah Soramarith Street, Kratie Province
ទូរស័ព្ទ-ទូរសារលេខ: (៨៥៥) ០៧២ ៩៧១ ៤២៧ / ០៧២ ៩៧១ ៤០៨
Phone-Fax: (855) 072 971 427 / 072 971 408 E-mail:admpda01@gmail.com